ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៤៧ /២៦-៥-២០០៩

សាលដីកា

លេខ : ៦៩ "ជ"/០១-៩-២០១០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យ លេខ០៦ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី ០១-៩-២០១០ ដែលមានសមាសភាពដូចខាងក្រោមនេះ

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

**តំណាងមហាអយ្យការ**

លោក **ម៉ែត សារ៉ាត**

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ : ២៤៧ ចុះថ្ងៃទី ២៦-៥-២០០៩ រវាង :

- ជនជាប់ចោទ ឈ្មោះ [redacted] **មិត្ត** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីកសិករ កើតនៅ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៧ ឃុំខ្លួនថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៧ តាមដីកាលេខ ៤០២ ដ ក ប ឃ ខ ។

ជាប់ចោទពីបទ : **មនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅ ភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

**ឯរឿងហេតុមានដូចតទៅ :**

នៅថ្ងៃទី ០៧-៤-២០០៧ ម៉ោង ២១:៤៥នាទី ឈ្មោះ [redacted] **ណាត** ភេទប្រុស អាយុ ២៣ឆ្នាំ នៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល បានផឹកស្រាស្រវឹងមកផ្ទះ អុកឡុកនឹងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះ ពេលនោះឈ្មោះ [redacted] **ឈឿន** ត្រូវជាឪពុក និងឈ្មោះ [redacted] **ធំ** ត្រូវជាម្តាយបានឡើងទៅឃាត់ឈ្មោះ [redacted] **ណាត** តែឈ្មោះ [redacted] **ណាត** មិនស្តាប់ ថែមទាំងវាយឪពុកម្តាយថែមទៀតផង ។ ពេលនោះឈ្មោះ [redacted] **មិត** ត្រូវជា ប្អូនបង្កើតរបស់ឈ្មោះ [redacted] **ណាត** បានកាន់ដំបងឬស្សីមួយមួយដៃ

ឡើងទៅលើផ្ទះវាយបងរបស់ខ្លួន ។

- **បានឃើញសាលក្រមព្រហ្មទណ្ឌលេខ : ០៣ "ព.ម" ចុះថ្ងៃទី ០៣-០២-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ :**

១- ផ្តន្ទាទោសឈ្មោះ [redacted] **ថិត្យ** ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ ១១ឆ្នាំ (ដប់មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៧ ។ ពីបទ : **មនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៧ ។

បទល្មើសដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- វត្ថុតាងមាន :

- ខោខូវប៊យចាស់ជើងវែង ពណ៌ផ្ទៃមេឃ ខ្សែក្រវ៉ាត់ ០១
- កាំបិតផ្គាក់ ០១ ដងឫស្សីមានប្រវែង ៦៣ ស.ម ដងប្រវែង ៣០.៧សម
- វណាដៃ (កន្ទុយត្រី) ចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល

៣- សាលក្រមនេះ ជំនុំជំរះ នឹងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវី និងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១០:៣០នាទីព្រឹក ។

បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

- សេចក្តីសំរេចនេះ ត្រូវបានឈ្មោះ [redacted] **ថិត្យ** ប្តឹងឧទ្ធរណ៍ កាលពីថ្ងៃទី ២៧-០២-២០០៩ រួចហើយ ។

- បានឃើញរបាយការណ៍ ចុះថ្ងៃទី ២៦-១០-២០០៩ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

- ជនជាប់ចោទ ឈ្មោះ [redacted] **ថិត្យ** "អវត្តមាន"

- មេធាវីលោក [redacted] **ចន្ថា** ការពារឱ្យជនជាប់ចោទ " វត្តមាន "

- ប្រធានក្រុមប្រឹក្សា ធ្វើការអធិប្បាយហេតុការណ៍ នៃរឿងដែលកើតមានឡើង និងអានសេចក្តីសំរេច របស់សាលាដំបូងខេត្តកណ្តាល ។

- **តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន** : បទល្មើសនេះ ជនជាប់ចោទប្រើកាំបិត មានចេតនាសំលាប់ ។ សូមតំកល់សាលក្រមព្រហ្មទណ្ឌ លេខ ០៣ (ព.ម) ចុះថ្ងៃទី ៣-២-២០០៩ របស់សាលាដំបូងខេត្តកណ្តាល ។

- **មេធាវីធ្វើសេចក្តីសន្និដ្ឋាន** : ក្រោយពីបានស្តាប់របាយការណ៍មក កូនក្តីខ្ញុំឈ្មោះ [redacted] **ថិត្យ** បានឡើងទៅឃាត់បងកុំឱ្យធ្វើ ចំពោះកាំបិតយកទៅពុំមានចេតនាសំលាប់ទេ ដោយមានការប្រវ៉ាយប្រតប់ ក៏ឃើញឈាម មិនដឹងថាត្រូវត្រង់ណាទេ គឺពុំមានចេតនាសំលាប់បងទេ ឪពុកម្តាយរបស់ជនជាប់ចោទ សុំឱ្យតុលាការមេត្តាអនុគ្រោះទោសដល់កូនគាត់ផង ។

**សំណូមពរ** : សូមលោកប្រធាន និងក្រុមប្រឹក្សាមេត្តាកែប្រែបទល្មើសពីចេតនា មកអចេតនា តាមមាត្រា ៤០វិញ ។

- ក្រោយពីបានអាន ចម្លើយជនជាប់ចោទ ។

- ក្រោយពីបានអាន ចម្លើយដើមបណ្ដឹង ។
- ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន ។
- ក្រោយពីបានស្ដាប់មេធាវីធ្វើសេចក្ដីសន្និដ្ឋាន ។
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

- យល់ឃើញថា :

១- បណ្ដឹងឧទ្ធរណ៍ លេខ ០៦ ចុះថ្ងៃ ២៧ កុម្ភៈ ២០០៩ របស់ជនជាប់ចោទ ឈ្មោះ [redacted] ទិះ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ ទទួលជំនុំជំរះបាន ។

២- មេធាវី [redacted] ចន្ធា ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- សាលាដំបូងខេត្តកណ្ដាលបានធ្វើការអង្កេត លើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់អស់ហើយ សាលាឧទ្ធរណ៍ ឯកភាពមិនលើកសំអាងហេតុដដែល មកបញ្ជាក់ជាថ្មីទៀតទេ ។

៤- សាលក្រមព្រហ្មទណ្ឌ លេខ ០៣ (ល.ម ) ចុះថ្ងៃ ៣-២-២០០៩ របស់សាលាដំបូងខេត្តកណ្ដា មាន លក្ខណៈត្រឹមត្រូវ ។ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍ លេខ ០៦ ចុះថ្ងៃ ២៧ កុម្ភៈ ២០០៩ របស់ជនជាប់ចោទ [redacted] ទិ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ០៣ (ល.ម) ចុះថ្ងៃ ៣-២-២០០៩ របស់សាលាដំបូងខេ កណ្ដាល ទុកជាបានការ ។

៣- អោយបន្តឃុំខ្លួន ជនជាប់ចោទ តាមមាត្រា ៣៥៣ និង ៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងចំពោះ មុខជនជាប់ចោទ ។

៧៧ថ

បើកផ្លូវប្ដឹងតវ៉ា តាមកំណត់ច្បាប់ ។

<u>សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់គ្រប់តំណែង និងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់</u> ។

ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា [redacted] ហត្ថលេខា [redacted] , [redacted] ហត្ថលេខា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ , ថ្ងៃ........ ខែ........ ឆ្នាំ ២០

បានឃើញ

ក្រឡាបញ្ជី

[redacted]

[redacted]